ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## ការប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងទិសដៅការងារ ខែមិថុនា ឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

នាព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង៨: ០០ នៅសាលសិក្ខាសាលាខាងត្បូង បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ និងថ្នាក់ដឹកនាំចាប់ពីប្រធាននាយកដ្ឋានឡើងចំនួន៤៥នាក់ ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមអគ្គលេខាធិការ** បានមានមតិស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងអង្គប្រជុំ និងបានបញ្ចាំងខ្សែវីដេអូអំពីសកម្មភាពការងាររបស់ព្រឹទ្ធសភាក្នុងយុទ្ធនាការប្រឆាំងជំងឺកូវីដ ១៩ ជូនអង្គប្រជុំទស្សនា និងផ្តល់យោបល់។ បន្ទាប់ពីបញ្ចប់ការ ទស្សនាខ្សែវីដេអូរួច **ឯកឧត្តមអគ្គលេខាធិការ** បានអនុញ្ញាតឱ្យឯកឧត្តម លោកជំទាវជា អគ្គនាយក និងអគ្គនាយិកា និងលោកជំទាវអគ្គាធិការ រាយការណ៍អំពីលទ្ធផលការងារសម្រេចបានក្នុងខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២០ ជូនអង្គប្រជុំជ្រាប ។

បន្ទាប់ពីស្តាប់របាយការណ៍របស់អគ្គនាយកដ្ឋានទាំង៥ និងអគ្គាធិការដ្ឋានរួចមក **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំអគ្គនាយកដ្ឋានទាំង៥ និងអង្គភាពចំណុះត្រូវរៀបចំ និងធ្វើបច្ចុប្បន្ន-ភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់ខ្លួន និងពិនិត្យអំពីគោលការណ៍៤ចំណុច (ចំណេះដឹង ជំនាញ បទពិសោធន៍ ស្នាដៃការងារ) សម្រាប់រៀបចំសមាសភាពថ្នាក់ដឹកនាំក្រោមឱវាទតាមឋានានុក្រម ព្រមទាំងកសាងផែនការយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់ខ្លួនៗ បន្ថែមពីនេះទៀត **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំឱ្យអង្គភាពសន្តិសុខសហការជាមួយគ្រប់អង្គភាពទាំងអស់ដោះស្រាយបញ្ហាអ្នកយករថយន្តមកចតចោលក្នុងបរិវេណព្រឹទ្ធសភា។ ក្នុងបរិបទនៃវិបត្តិ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ជំងឺកូវីដ១៩ **ឯកឧត្តម** បានណែនាំឱ្យគ្រប់អង្គភាពថវិកាតាមកម្មវិធីទាំងអស់ធ្វើវិចារណកម្មចំណាយឱ្យបានត្រឹមត្រូវ ដើម្បីកាត់បន្ថយការចំណាយផ្សេងៗ និងជំរុញឱ្យគ្រប់អង្គភាពប្រើង-ប្រែងប្រែក្លាយការគំរាមកំហែងឱ្យទៅជាឱកាសតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (Zoom និងរដ្ឋបាលអេឡិចត្រូនិក)។ ជាកិច្ចបន្ត **ឯកឧត្តមអគ្គលេខាធិការ** បានមានប្រសាសន៍ជម្រាបជូនអំពីព្រឹត្តិការណ៍ជាតិ តំបន់ និងពិភពលោក ដើម្បីជាមូលដ្ឋានក្នុងការបំពេញការងារឱ្យស្របតាមស្ថានភាពនៃការវិវឌ្ឍថ្មីៗនៃសភាពការណ៍លើសកលលោក និងរាយការណ៍អំពីលទ្ធផលការងារដែលសម្រេចបានដូចខាងក្រោមៈ

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**១-មុខងារនីតិកម្ម**

-បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក ដើម្បីពិនិត្យសម្រេចលើការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាលើកទី២ ក្នុងក្របខ័ណ្ឌច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងរចនាសម្ព័ន្ធថ្មី របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឱ្យបានស្របនឹងតម្រូវការថ្មីរបស់ស្ថាប័ន ។

**២-មុខងារតំណាង**

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា បានអញ្ជើញជាអធិបតី និងចូលរួមក្នុងពិធីផ្សេងៗរួមមានៈ

+ទទួលព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ស្តេចយាងនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិនមកមាតុប្រទេសវិញ

+គោរពវិញ្ញាណក្ខន្ធ ពិធីបញ្ចុះសព និងបុណ្យទក្ខិណានុប្បទានគម្រប់៧ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធអ្នកឧកញ៉ាព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** នៅខេត្តត្បូងឃ្មុំ

+គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅរាជធានីភ្នំពេញ

+ចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយប្រជាពលរដ្ឋ មន្ត្រី និងអាជ្ញាធរមូលដ្ឋាន នៅរាជធានីភ្នំពេញ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

-ឯកឧត្តម **ស៊ឹម កា** ប្រធានស្ដីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីបូជាសព ឯកឧត្តម **កែវ ធី** ទីប្រឹក្សាសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធ និងពិធីបញ្ចុះសពអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** និងពិធីបូជាសពឯកឧត្តម **កែវ ធី** ទីប្រឹក្សាសម្ដេចប្រធានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តត្បូងឃ្មុំ

-ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងចូលរួមពិធីផ្សេងៗនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ កំពត កំពង់ធំ មណ្ឌលគិរី បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីប្រគល់-ទទួលអំណោយមនុស្សធម៌ជាបរិក្ខារប្រើប្រាស់ពីឯកឧត្តម ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក គឹម រតនា ប្រធានអង្គការការីតាស ជូនដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩

-ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ទៅប្រគល់ជូនអាជ្ញាធរសង្កាត់ព្រែកលៀប សង្កាត់ព្រែកតាសេក និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីរួមចំណែកក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ ១៩

-ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីប្រគល់-ទទួលអំណោយម៉ាសជាជំនួយរបស់រដ្ឋសភាវៀតណាមជូនដល់ព្រឹទ្ធសភា-រដ្ឋសភាកម្ពុជា ។

**៣-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-សម្តេចវិបុលសេនាភក្តី ***សាយ ឈុំ*** ប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចូលជួបសម្តែងការគួរសម និងសវនាការ ។

**៤-មុខងារអភិវឌ្ឍស្ថាប័ន**

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រឆាំងជំងឺកូវីដ១៩

-បន្តយកចិត្តទុកដាក់ការងារអនាម័យ បរិស្ថាន សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ។ល។

-ការបង្កើយគម្រោងជួសជុលនិងកែលម្អអគារមួយចំនួន ការងារសន្តិសុខ និងសណ្តាប់ធ្នាប់

-ការបន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom សន្តិសុខបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធសម្លេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិក ការងារព័ត៌មាន ការផលិតខ្សែវីដេអូ និងការបោះពុម្ព

-ការអភិវឌ្ឍសមត្ថភាពមន្ត្រីពជការៈចំណេះដឹង ជំនាញភាសា គ្រប់គ្រង ដឹកនាំ បច្ចេក-វិទ្យាព័ត៌មាន

-ការបន្តយកចិត្តទុកដាក់មជ្ឈដ្ឋានដែលនៅខ្សោយ និងសមត្ថភាពផលិតសេវានៅទាប

-សិក្សាការរៀបចំ PCA ដំណាក់កាលបន្ទាប់ពី PIC ការរៀបចំ Legal Database របស់ព្រឹទ្ធសភា

-សិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានាឱ្យបានសមស្របនឹងដំណាក់កាលថ្មី

-ធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច សមត្ថកិច្ចរបស់អគ្គនាយដ្ឋានទាំង៥ និងអង្គភាពចំណុះ ព្រមទាំងសមាសភាពដឹកនាំក្រោមឱវាទតាមឋានានុក្រម

-ធ្វើបច្ចុប្បន្នភាពបៀវត្ស និងផលប្រយោជន៍តាមការប្រែប្រួលថ្មី បង្កើនសមត្ថភាពស្រាវជ្រាវ និងផលិតឯកសារ

-ការបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល ដើម្បីទ្រទ្រង់ដំណើរការថវិការហូតដល់ចុងឆ្នាំ២០២០

-ប្រជុំពិនិត្យ និងពិភាក្សាស្តីពី ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាលើកទី២ ក្នុងក្របខ័ណ្ឌ

ច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

-ប្រជុំផ្សព្វផ្សាយស្ដីពី ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០២១-២០៣០) និងទស្សនៈវិស័យនៃដំណើរការទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០២១-២០៣០)

-ប្រជុំការងារកសាងផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់អគ្គនាយកដ្ឋានទាំង៥ ឱ្យបានចប់នៅត្រឹមចំណាច់ខែមិថុនា ឆ្នាំ២០២០

-ប្រជុំផ្សព្វផ្សាយស្ដីពី រចនាសម្ព័ន្ធថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ប្រជុំពិនិត្យស្ដីពី ការងារសង្គមកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ប្រជុំពិនិត្យស្ដីពី ការងារសវនកម្មផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

## II.**ទិសដៅការងារសម្រាប់ខែមិថុនា ឆ្នាំ២០២០**

### ១-សេវាទ្រទ្រង់មុខងារនីតិកម្ម ៖

-ការសិក្សាអំពីករណី នៃការប្រកាសភាពអាសន្ន និងឥទ្ធិពលមកលើដំណើរការរបស់ព្រឹទ្ធសភា ។

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី៤ ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

៤-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និងការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងម៉ាឡេស៊ី

៥-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការគេចវេះពន្ធ និង

ការបោះពុម្ពផ្សាយ ការចៀសវាងពន្ធរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាទីក្រុងប៊ែនស្តីពី កិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈឆ្នាំ១៨៨៦ និងវិសោធនកម្ម ។

**២-សេវាទ្រទ្រង់មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ៖**

ត្រៀមសហការ និងសម្របសម្រួលការងារជូនគណៈកម្មការជំនាញ ជំនួបសវនាការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ។

**៣-សេវាទ្រទ្រង់មុខងារតំណាង៖**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ។

**៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបផ្លូវការរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានា

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ។

**៥-ការអភិវឌ្ឍស្ថាប័ន៖**

-ត្រៀមរៀបចំគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២១

-រៀបចំធ្វើបច្ចុប្បន្នភាពគោលការណ៍ហិរញ្ញវត្ថុសំខាន់ៗ និងថវិកាតាមកម្មវិធី អគ្គនាយកដ្ឋាន នាយកដ្ឋាន និងគ្រប់អង្គភាពចំណុះទាំងអស់ ត្រូវរៀបចំយន្តការការងារតាមប្រព័ន្ធ Online ដើម្បីធានាគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងស័ក្តិសិទ្ធិភាព ជូនស្ថាប័នឱ្យបានល្អប្រសើរ

-បង្កើនការគ្រប់គ្រងអគារ សារពើភ័ណ្ឌ និងការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃ ទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ INTERNET

-បន្តថែរក្សាហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាននៅក្នុងព្រឹទ្ធសភា

-រៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធី

Eបណ្ណាល័យ និង Eបណ្ណសារ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការផ្សេងៗ

-បន្តសហការជាមួយក្រុមការងារFMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់

-រៀបចំផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានទាំង៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍ ICT អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-បន្តប្រជុំគណៈកម្មការគោលការណ៍ គោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បង្កើនការបញ្ចូលប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងគ្រប់វិស័យនៃការងាររបស់ស្ថាប័ន ។

### *សេចក្តីសន្និដ្ឋាន*

ខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តការយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រឆាំងជំងឺកូវីដ១៩។ ស្របជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន បានកែសម្រួលរចនាសម្ព័ន្ធថ្មី ដើម្បីពង្រឹងគុណវុឌ្ឍិការងារឱ្យកាន់តែមានគុណភាព និងស័ក្តិសិទ្ធិភាពស្របតាមស្ថានភាព និងតម្រូវការចាំបាច់របស់ស្ថាប័ន។ ដោយឡែកការរៀបចំ និងចាត់ចែងការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា លើសេវាទ្រទ្រង់មុខងារនីតិកម្ម ប្រជុំគណៈកម្មាធិការ-អចិន្ត្រៃយ៍ចំនួន០២លើក បានយ៉ាងល្អប្រសើរ ។

ទន្ទឹមនឹងនេះ លើមុខងារតំណាងបានអមដំណើរសមាជិកព្រឹទ្ធសភា ចុះបេសកម្មតាមមូលដ្ឋាន ដើម្បីសាកសួរសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជា-ពលរដ្ឋ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានា។ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្ត លើកកម្ពស់ការផ្តល់សេវាស្រាវជ្រាវ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធ Online ក្នុងប្រតិបត្តិការការងារប្រចាំថ្ងៃ ។

ការសន្សំសំចៃ បានតម្រូវឱ្យកាត់បន្ថយចំណាយប្រតិបត្តិការលើមុខងារទាំងឡាយបន្ថែមទៀត ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១.៣០ នាទីព្រឹក ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល ប្រកបដោយស្មារតីទទួលខុសត្រូវ ។

ថ្ងៃព្រហស្បតិ៍ [illegible]កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០២០

**ប្រធាននាយកដ្ឋាន**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការ**

**អ៊ុំ_សារឹទ្ធ**

**បានឃើញ និងឯកភាព**

**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**

**ឡាំង ថ៉ន**